ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ០១៤/២៥ ប្រក..... អអរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម ឡរ៉េន វ៉ុង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី នៅព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តម **ឡរ៉េន វ៉ុង (LAWRENCE WONG)** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី និងលោកជំទាវ រួមទាំងគណៈប្រតិភូរដ្ឋាភិបាលសិង្ហបុរី បានអញ្ជើញធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសសិង្ហបុរីវិញ នៅល្ងាចថ្ងៃពុធ ទី២ ខែកក្កដា ឆ្នាំ២០២៥ នេះ បន្ទាប់ពីបានបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា រយៈពេល១ថ្ងៃ តបតាមការអញ្ជើញរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជានេះ ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី និងលោកជំទាវ រួមទាំងគណៈប្រតិភូ បានអញ្ជើញចូលក្រាបថ្វាយបង្គំគាល់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង និងជំនួបសម្តែងការគួរសមជាមួយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងជំនួបទ្វេភាគីជាមួយ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

### ជំនួបទ្វេភាគី

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** បានដឹកនាំគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងអញ្ជើញធ្វើបដិសណ្ឋារកិច្ចផ្លូវការប្រកបដោយកិត្តិយសជូន ឯកឧត្តម **ឡរ៉េន វ៉ុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី និងលោកជំទាវ រួមទាំងគណៈប្រតិភូ នៅវិមានសន្តិភាព។

តាមរយៈជំនួបនេះ សម្តេចធិបតី បានសម្តែងនូវក្តីសោមនស្សរីករាយដែលបានជួបពិភាក្សាការងារជាមួយ ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី ក្នុងឱកាសនៃការបំពេញទស្សនកិច្ចផ្លូវការលើកដំបូងនៅកម្ពុជា និងបានសម្តែងការអបអរសាទរជាថ្មីម្តងទៀតចំពោះជ័យជំនះរបស់ ឯកឧត្តម និងគណបក្ស People's Action Party ក្នុងការបោះឆ្នោតនាពេលថ្មីៗនេះ។

ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី ក៏បានថ្លែងអំណរគុណ សម្តេចធិបតី យ៉ាងជ្រាលជ្រៅចំពោះការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ ឯកឧត្តម និងលោកជំទាវ ព្រមទាំងគណៈប្រតិភូ។ ឯកឧត្តមនាយករដ្ឋមន្ត្រី បានបញ្ជាក់ថា

ដំណើរទស្សនកិច្ចមកកាន់ព្រះរាជាណាចក្រកម្ពុជានាពេលនេះ ស្របពេលខួបទី៦០ នៃការបង្កើតទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ និងបានឆ្លុះបញ្ចាំងអំពីភាពជាដៃគូយូរអង្វែងនិងរឹងមាំរវាងប្រទេសទាំងពីរ ក្នុងពេលបច្ចុប្បន្ននិងអនាគត។

**ថ្នាក់ដឹកនាំទាំងពីរ** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អ យូរអង្វែង និងប្រកបដោយផ្លែផ្កាវវាងកម្ពុជា-សិង្ហបុរី ព្រមទាំងសម្តែងក្តីរីករាយ និងស្វាគមន៍ចំពោះការរៀបចំនូវព្រឹត្តិការណ៍នានាដើម្បីអបអរសាទរខួបទី៦០ នៃការបង្កើតទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ។ **ថ្នាក់ដឹកនាំទាំងពីរ** បានវាយតម្លៃខ្ពស់អំពីការសម្រេចបាននូវសមិទ្ធផលជាច្រើន ដែលកើតចេញពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់កម្រិត និងគ្រប់វិស័យ ព្រមទាំងប្តេជ្ញាបន្តជំរុញពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធនេះឱ្យកាន់តែរឹងមាំបន្ថែមទៀត។ បន្ថែមលើនេះ **ថ្នាក់ដឹកនាំទាំងពីរ** បានពិភាក្សានិងឯកភាពគ្នាក្នុងការបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗជាច្រើន រួមមាន ពាណិជ្ជកម្ម វិនិយោគនិងហិរញ្ញវត្ថុ ការតភ្ជាប់ប្រជាជននិងប្រជាជន ការពារជាតិនិងសន្តិសុខ កសិកម្ម សន្តិសុខស្បៀងនិងថាមពល និងការបណ្តុះបណ្តាលជំនាញនិងវិជ្ជាជីវៈ។ ទន្ទឹមនឹងនេះ **ថ្នាក់ដឹកនាំទាំងពីរ** ក៏បានពិភាក្សានិងផ្លាស់ប្តូរយោបល់គ្នាអំពីកិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ដើម្បីជាឧត្តមប្រយោជន៍នៃប្រទេសនិងប្រជាជនទាំងពីរ។

បន្ទាប់ពីជំនួបទ្វេភាគីនោះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត** បានរៀបចំពិធីជប់លៀងផ្លូវការជូន **ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី និងលោកជំទាវ** ព្រមទាំងគណៈប្រតិភូ នៅវិមានសន្តិភាព។

## ជំនួបសម្តែងការគួរសម

នៅវិមានព្រឹទ្ធសភា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ **ឯកឧត្តម ឡរ៉េន វ៉ុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី **និងលោកជំទាវ** ព្រមទាំងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នាពេលនេះ។ **សម្តេចតេជោប្រធានព្រឹទ្ធសភា** បានចាត់ទុកដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី** ជាផ្នែកមួយដ៏សំខាន់ នៃការជំរុញទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា-សិង្ហបុរី ឱ្យកាន់តែល្អប្រសើររីកចម្រើនបន្ថែមទៀត។ **សម្តេចតេជោ** មានប្រសាសន៍ថា ទំនាក់ទំនងល្អរវាងកម្ពុជា-សិង្ហបុរី មានភាពរីកចម្រើននិងមានលក្ខណៈយូរអង្វែងចាប់តាំងពី **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** និង **ឯកឧត្តម លី ក្វាន់យូ នាយករដ្ឋមន្ត្រីដំបូងបំផុតរបស់សិង្ហបុរី** កាលពី៦០ឆ្នាំមុន បន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ។ **សម្តេចតេជោ** ជំរុញឱ្យប្រទេសទាំងពីរបង្កើនជើងហោះហើរទៅវិញទៅមកកាន់តែច្រើនបន្ថែមទៀតដើម្បីពង្រីកវិស័យទេសចរណ៍ ខណៈកម្ពុជាគ្រោងដាក់ឱ្យដំណើរការអាកាសយានដ្ឋានអន្តរជាតិតេជោ នាពេលឆាប់ៗខាងមុខ។ **សម្តេចតេជោ** ក៏បានចែករំលែកអំពីស្ថានភាពបញ្ហាព្រំដែនកម្ពុជា-ថៃ និងបានបញ្ជាក់ពីគោលជំហររបស់កម្ពុជា គឺមិនចង់មានសង្គ្រាមជាមួយប្រទេសជិតខាងនោះទេ កម្ពុជាចង់ដោះស្រាយបញ្ហាដោយសន្តិវិធី និងឈរលើគោលការណ៍ច្បាប់អន្តរជាតិ។

**ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី** ចាត់ទុក **សម្តេចតេជោ** ជាតួអង្គមួយដែលបានពង្រីកនិងគូនផ្ចុំទំនាក់ទំនងរវាងកម្ពុជា-សិង្ហបុរី ឱ្យកាន់តែមានការរីកចម្រើនឡើង។ **ឯកឧត្តម** ក៏យល់ស្របចំពោះការដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី និងយន្តការច្បាប់អន្តរជាតិ ដោយសង្ឃឹមថា សន្តិភាពនឹងកើតឡើងនៅក្នុងតំបន់អាស៊ាន។

ក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជានេះ **ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី** រួមទាំងគណៈប្រតិភូ ក៏បានអញ្ជើញដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងនៅមណ្ឌប ព្រះបរមរូប ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** "ព្រះបរមរតនកោដ្ឋ" អតីតព្រះមហាវីរក្សត្រ **នៃព្រះរាជាណាចក្រកម្ពុជា។**

ក្នុងអំឡុងដំណើរទស្សនកិច្ចផ្លូវការនេះ លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អញ្ជើញរួមដំណើរជាមួយ លោកជំទាវ **ជីលុយ លូ** ភរិយា ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី អញ្ជើញទស្សនកិច្ចសារមន្ទីរជាតិនៃកម្ពុជា នៅរាជធានីភ្នំពេញ។

គួរកត់សម្គាល់ថា ដំណើរទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម **ឡរ៉េន វ៉ុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋ **សិង្ហបុរី** នៅកម្ពុជានាពេលនេះ បង្ហាញឱ្យឃើញពីតួនាទីកាន់តែសំខាន់របស់កម្ពុជានៅក្នុងតំបន់ ជាពិសេសបង្ហាញពីទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងកម្ពុជានិងសិង្ហបុរី។ ដំណើរទស្សនកិច្ចនេះ គឺជាឧទាហរណ៍ជាក់ស្តែងមួយទៀត សបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជា បានទទួលជោគជ័យកាន់តែខ្លាំងឡើងជាលំដាប់នៅក្នុងនយោបាយការទូតរបស់ខ្លួន ដោយកសាងបានទំនាក់ទំនងល្អ និងកាន់តែស៊ីជម្រៅជាមួយបណ្តាប្រទេសជាមិត្តនៅគ្រប់ជ្រុងជ្រោយនៃពិភពលោក។ ដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋាភិបាលសិង្ហបុរី ក៏បានពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពជាប្រពៃណីដ៏ល្អដែលមានស្រាប់ និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ប្រទេសនិងប្រជាជនទាំងពីរ។

ថ្ងៃពុធ ៧កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥